# ឯកសារគោលជំហររួម
# ស្តីពី
# ការអនុវត្តច្បាប់និងគោលនយោបាយនានា
# ដែលទាក់ទងទៅនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព
## ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឯកសារគោលជំហររួមគឺជាសេចក្តីថ្លែងការណ៍រួមរវាងអង្គការសង្គមស៊ីវិលដែលកំពុងអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលទទួលបាននូវមោទនៈភាពក្នុងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ និងទទួលស្គាល់ជាលក្ខណៈជាតិនិងអន្តរជាតិ នូវអត្រានៃការផ្ទុកមេរោគអេដស៍ចុះមកត្រឹម០.៨%នៅឆ្នាំ២០១០។ សមិទ្ធផលនេះអាចសម្រេចទៅបានដោយសារតែគ្រប់ស្ថាប័នទាំងអស់ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា បានបង្ករឱ្យមានការចូលរួមជាពហុវិស័យពីគ្រប់ស្ថាប័នទាំងអស់ជាពិសេសដល់សង្គមស៊ីវិលឱ្យបានរួមចំណែក ក្នុងកិច្ចការងារនេះជាមួយរដ្ឋាភិបាល។ ច្បាប់ គោលនយោបាយ គោលការណ៍ណែនាំ និងនិយាមបែបបទនៃការអនុវត្តនានា ត្រូវបានបង្កើតឡើងដើម្បីជាមធ្យោបាយក្នុងការអនុវត្តសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍។

ទន្ទឹមនឹងភាពជោគជ័យនេះ កម្ពុជាក៏បានជួបប្រទះនូវឧបសគ្គខ្លះៗផងដែរ ដែលទាក់ទងនឹងការអនុវត្តច្បាប់ គោលនយោបាយ គោលការណែនាំ ដែលច្បាប់និងគោលនយោបាយទាំងនោះរួមមានៈ ច្បាប់ស្តីពីប្រឆាំងនឹងការជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៥ និងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ឆ្នាំ២០១០។គោលការណ៍ទាំងនោះមានផ្នែកខ្លះប៉ះពាល់ដល់វិស័យសុខភាពសាធារណៈ ជាពិសេសកម្មវិធីបង្ការការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍។ ការបកស្រាយ និងការអនុវត្តច្បាប់និងគោលនយោបាយទាំងនោះតែងតែមានទំនាស់ផលប្រយោជន៍ជាមួយក្រុមស្ត្រីបម្រើសេវាកម្សាន្ត ក្រុមស្រីស្រស់ បុរសស្រលាញ់បុរស និងក្រុមអ្នករងគ្រោះដោយគ្រឿងញៀន។

- មានមាត្រាចំនួន៨ (មាត្រា២៣ ២៤ ២៥ ២៦ ២៧ ៣០ និង៣១)នៃច្បាប់ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទដែលបានដាក់អំពើពេស្យាចារសម្រាប់មនុស្សពេញវ័យឱ្យនៅក្រៅច្បាប់ ឬផ្នែកមួយនៃអំពើពេស្យាចារ។ ច្បាប់នេះមិនបានកំណត់ច្បាស់លាស់ថាអ្នករកស៊ីផ្លូវភេទគឺជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ច្បាប់នេះក៏បង្កើតឱ្យមានការភ័ន្តច្រលំផងដែរនូវពាក្យពេស្យាចារ និងអំពើជួញដូរមនុស្ស។
- ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀនបានអនុញ្ញាតិឱ្យប៉ូលីសចាប់អ្នកប្រើប្រាស់គ្រឿងញៀន ហើយគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពបានដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការចាប់ខ្លួនអ្នករងគ្រោះដោយគ្រឿងញៀន និងអ្នករកស៊ីផ្លូវភេទ។

- ជាសញ្ញាមួយក្នុងការចាប់ខ្លួន ឃុំខ្លួន និងការប្រើអំពោះហឹង្សាលើអ្នករកស៊ីផ្លូវភេទ ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងអ្នករងគ្រោះដោយគ្រឿងញៀន។ អត្រាឆ្លងកាមរោគ និងមេរោគអេដស៍ ការរំលូតកូនក្នុងចំណោមអ្នករកស៊ីផ្លូវភេទតាមផ្ទះបននិងក្រៅផ្ទះបនមានការកើនឡើង ការប្រើប្រាស់ស្រោមអនាម័យមានការថយចុះ និងពិបាកក្នុងការទទួលបាននូវស្រោមអនាម័យ ចាប់តាំងពីពេលដែលច្បាប់និងគោលនយោបាយទាំងនោះអនុវត្ត។
- កម្រិតជីវភាពរបស់អ្នករកស៊ីផ្លូវភេទធ្លាក់ចុះ ការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ឱ្យនៅជាច់ដោយឡែកសម្រាប់ក្រុមអ្នករស៊ីផ្លូវភេទដោយស្ម័គ្រចិត្ត ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងក្រុមរងគ្រោះដោយគ្រឿងញៀន។ ពួកគេបានប្រានចោលការទទួលសេវាថែទាំសុខភាព ការទទួលបានឱសថប្រឆាំងមេរោគអេដស៍ និងការព្យាបាលដល់អ្នករងគ្រោះដោយគ្រឿងញៀនគឺជាការរំលោភសិទ្ធិមនុស្ស។
- ក្រុមអ្នករស៊ីផ្លូវភេទ ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងក្រុមរងគ្រោះដោយគ្រឿងញៀន គឺមានភាពងាយរងគ្រោះណាស់ក្នុងការឆ្លងមេរោគអេដស៍ និងកាមរោគ។ អ្នកជំនាញផ្នែកសុខភាពសាធារណៈជឿជាក់ថាកិច្ចសហការក្នុងចំណោមសហគមន៍ពួកគេដោយផ្ទាល់ ជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការបញ្ច្រាប និងចែករម្លែកការបង្ការការរីករាលដាលមេរោគអេដស៍ និងជំងឺកាមរោគ។
- លើកកំពស់បរិយាកាសគាំទ្រដៃគូរសហគមន៍សម្រាប់ អង្គការសមាគម សហជីព នឹងបណ្តាញនៃអ្នករកស៊ីផ្លូវភេទ ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងក្រុមរងគ្រោះដោយគ្រឿងញៀន អាចជាយុទ្ធសាស្ត្របង្ការមេរោគអេដស៍ និងអាចកាត់ផ្តាច់ការទំនាក់ទំនងជាមួយអ្នករកស៊ីផ្លូវភេទ រាប់បញ្ចូលទាំងអំពើហឹង្សា ការបៀតបៀនពីសំណាក់មន្ត្រីនគរបាល ការមានផ្ទៃពោះដោយចៃដន្យ និងពេស្យាចារកុមារ។ បច្ចុប្បន្ននេះអង្គការសង្គមសីវិល មានការពិបាកក្នុងការស្វែងរកក្រុមគោលដៅដើម្បីធ្វើការអប់រំ ថែទាំ និងគាំទ្រ។
- អនុវត្តនូវគោលនយោបាយអង្គការសុខភាពពិភពលោកលើការបង្ការ ថែទាំគាំទ្រ ស្តីពីការងាររបស់អ្នករកស៊ីផ្លូវភេទ[1] ដែលរៀបចំឡើងដោយអង្គការសុខភាពពិភពលោកបានបង្ហាញនូវគោលការណ៍សំខាន់ៗមួយចំនួនដូចជា ការកំណត់ឥរិយាបថដែលមិនមានការវិនិច្ឆ័យជាមុន ធ្វើឱ្យប្រាកដថាបទអន្តរាគមន៍គ្មានការរំខាន គោរពទស្សនៈរបស់អ្នករកស៊ីផ្លូវភេទ ចំណេះដឹង និងបទពិសោធន៍ជីវិត និងការចូលរួមរបស់អ្នករកស៊ីផ្លូវភេទក្នុងបទអន្តរាគមន៍និងការអនុវត្តវិធីសាស្ត្រសម្រាប់កិច្ចការបង្ការមេរោគអេដស៍ជំងឺអេដស៍ក្នុងបរិបថអ្នករកស៊ីផ្លូវភេទ។

សញ្ញានៃគ្រោះថ្នាក់ក្នុងវិស័យសុខភាពសាធារណៈបានកើតមានឡើង យើងជាអង្គការសង្គមស៊ីវិលសូមលើកជាអនុសាសន៍ជូនរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតនូវៈ

- ពិនិត្យឡើងវិញនូវច្បាប់និងគោលនយោបាយខាងក្រោម

[1] The World Health Organization, *Sex Work Tool Kit: Targeted HIV/AIDS Prevention and Care in Sex Work Settings 2007*

- ធ្វើវិសោធនកម្ម លើមាត្រាមួយចំនួនដែលបានបញ្ជាក់ខាងដើម។ និងចេញសេចក្តីពន្យល់នៃច្បាប់ស្តីពីបង្ក្រាបការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឱ្យបានច្បាស់លាស់និងការអនុវត្តច្បាប់ ជារួមមួយ ដើម្បីធានាថាការអនុវត្តគ្មានផលប៉ះពាល់។
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពគួរតែធ្វើវិសោធនកម្មដើម្បីឱ្យស្របទៅតាមយុទ្ធសាស្ត្រនៃការកាត់បន្ថយផលប៉ះពាល់នៃគ្រឿងញៀន។
- អាជ្ញាធរមូលដ្ឋាន នគរបាលជាតិ និងសង្គមស៊ីវិលគួរតែលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តការល្អ និងចែករំលែកព័ត៌មាន។ នគរបាលជាតិ និងអាជ្ញាធរមូលដ្ឋានគួរតែបញ្ឈប់ការចាប់ ការឃុំខ្លួនអ្នករកស៊ីផ្លូវភេទ ស្រីស្រស់ បុរសស្រលាញ់បុរស និងអ្នករងគ្រោះដោយគ្រឿងញៀន។
- បង្ករបរិយាកាសល្អសម្រាប់អង្គការ សមាគម និងសហជីពដើម្បីផ្តល់នូវការគាំទ្រផ្នែកសុខភាពសង្គម និងសេវាកម្មច្បាប់អ្នករកស៊ីផ្លូវភេទ ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងក្រុមរងគ្រោះដោយគ្រឿងញៀន។

- បង្កើតឱ្យមានយន្តការត្រួតពិនិត្យមួយដែលមានប្រសិទ្ធភាព (ឧបករណ៍តាមដាន ប្រព័ន្ធ និងទិន្នន័យ)
  - បង្កើតនូវគោលការណ៍ណែនាំអនុវត្តច្បាប់និងគោលនយោបាយទាំងនេះ
  - បង្កើតនូវកម្មវិធីសិក្សាមួយសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ មន្ត្រីយុត្តិធម៌ និងអាជ្ញាធរមូលដ្ឋានអំពីការអនុវត្តច្បាប់និងគោលនយោបាយ
  - រៀបចំឱ្យមានការសិក្សាថ្នាក់ជាតិមួយ អំពីផលប៉ះពាល់នៃការអនុវត្តច្បាប់និងគោលនយោបាយទៅលើអ្នករកស៊ីផ្លូវភេទ ក្រុមស្រីស្រស់ ក្រុមបុរសស្រលាញ់បុរស និងក្រុមរងគ្រោះដោយគ្រឿងញៀន